
www.kidsofdestiny.org
Kids of Destiny©
Reaching the Next Generation

## 2.09 បុណ្យរំលងលើកទីមួយ

ប្រជាជនរបស់ព្រះ ដែលជាជនជាតិអ៊ីស្រាអែល បានរស់នៅក្នុងប្រទេសអេស៊ីព្ទ ។ ពួកគេបានធ្វើការយ៉ាងលំបាកជាខ្លាំងសម្រាប់មេដឹកនាំប្រទេសនោះ ។ គាត់ត្រូវបានគេហៅថា ផារ៉ោន ។ ប្រជាជនអ៊ីស្រាអែលបានអធិស្ឋានសុំជំនួយមកពីព្រះ ។ ពួកគេបានអធិស្ឋានក្នុងរយៈពេលជាយូរណាស់មកហើយ ។ នៅពេលនោះ ក៏មានបុរសម្នាក់ឈ្មោះម៉ូសេ ។ គាត់ជាអ្នកដែលស្រឡាញ់ព្រះ ហើយព្រះអម្ចាស់ក៏ស្រឡាញ់គាត់ដែរ ។ នៅថ្ងៃមួយ ព្រះទ្រង់បានប្រាប់ម៉ូសេថា ទ្រង់មានការងារមួយ ដើម្បីឲ្យគាត់ធ្វើ ។ លោកម៉ូសេបានព្រួយបារម្ភថាគាត់មិនអាចធ្វើកិច្ចការទាំងអស់បានទេ ដូច្នេះ ព្រះទ្រង់បានមានបន្ទូលថា ម៉ូសេអាចនាំអើរ៉ុន ដែលជាបងប្រុសរបស់គាត់មកជួយគាត់បាន។ ព្រះបានប្រាប់ម៉ូសេនិងអើរ៉ុនថា នេះគឺជាការងាររបស់ពួកគេ៖ ពួកគេត្រូវទៅស្រុកអេស៊ីព្ទ ដើម្បីទៅជួយ សង្គ្រោះប្រជាជនអ៊ីស្រាអែលពីស្តេចផារ៉ោន។ ប៉ុន្តែមុនដំបូង ស្តេចផារ៉ោនត្រូវបញ្ចុះបញ្ចូល ដើម្បីអនុញ្ញាតឲ្យប្រជាជនអ៊ីស្រាអែលចាកចេញពីស្រុកនោះ។ ព្រះទ្រង់មានផែនការមួយ ដើម្បីធ្វើឱ្យស្តេចផារ៉ោនដោះលែងប្រជាជនទ្រង់ ។ ទ្រង់បានរៀបចំគម្រោងអាក្រក់ ១០យ៉ាងដែលហៅថាគ្រោះកាច ដើម្បីមកឯប្រជាជនអេស៊ីព្ទ ដូច្នេះផារ៉ោននឹងឃើញថា ព្រះទ្រង់មានឫទ្ធានុភាពខ្លាំងជាងគាត់ ។ ព្រះបានប្រាប់ម៉ូសេនិងអើរ៉ុនឲ្យព្រមានស្តេចផារ៉ោនអំពីគ្រោះកាចនីមួយៗ ។ ប៉ុន្តែ ស្តេចផារ៉ោនជាមនុស្សរឹងចចេះណាស់ហើយបានបង្ខាំង មិនឲ្យជនជាតិអ៊ីស្រាអែលចាកចេញឡើយ ។

1. គ្រោះកាចទី១ គឺទឹកនៅក្នុងស្រុកអេស៊ីព្ទប្រែទៅជាឈាម ។ វាបានកើតឡើងនៅគ្រប់ទីកន្លែង ។ គ្មានទឹកស្អាតនៅកន្លែងណាទេ ។

2. គ្រោះកាចទី២ គឺបាននាំយកសត្វកង្កែបមក ។ មានកង្កែបជាច្រើនសន្ធឹកណាស់ ។ ទាំងនៅក្នុងផ្ទះនៅលើគ្រែនៅពេលមនុស្សព្យាយាមដើរទៅតាមផ្លូវក៏មានដែរ ។

3. ទី៣ គឺសត្វចៃ ។ 4. ទី៤ គឺសត្វរុយ ។

5. គ្រោះកាចទី៥ គឺបណ្តាលឱ្យសត្វក្នុងកសិដ្ឋានស្លាប់។ ស្តេចផារ៉ោននៅតែមានរាជឱង្ការថា៖ «យល់ព្រម! អ្នកអាចយកប្រជាជនទៅបានហើយ។ហើយបញ្ឈប់គ្រោះកាចទាំងនោះទៅ!ប៉ុន្តែភ្លាមៗនៅពេលអ្វីៗវិលត្រឡប់មករកសភាពដើមវិញស្តេចបានផ្លាស់ប្តូរគំនិតវិញ

6. គ្រោះកាចទី៦ គឺមានកើតដំបៅពេញខ្លួនមនុស្ស ។ 7. គ្រោះកាចទី៧ គឺជាព្រឹលទឹកកកធំៗ ធ្លាក់ចុះពីលើមេឃមក ។

8. ទី៨ គឺមានសត្វកណ្តូបជាច្រើនធ្វើឲ្យប្រជាជនខឹង ដោយបានស៊ីដំណាំខ្ទេច ។

9. ទី៩ គឺមានងងឹតអស់រយៈពេលបីថ្ងៃ នៅទូទាំងស្រុកអេស៊ីព្ទទាំងមូល គឺគ្មានពន្លឺថ្ងៃទាល់តែសោះ ។

10. ប៉ុន្តែ គ្រោះកាចទី១០ គឺអាក្រក់បំផុត ។ ព្រះទ្រង់បានប្រាប់ផារ៉ោនថា កូនច្បងក្នុងគ្រួសារទាំងអស់នឹងត្រូវស្លាប់ ។ នេះគឺធ្ងន់ធ្ងរណាស់ ។ ប្រជាជនអ៊ីស្រាអែលបានស្តាប់តាមព្រះ ។ ទ្រង់បានការពារពួកគេ ពីគ្រោះកាចទាំងអស់ ។ វាពិតជាសំខាន់ខ្លាំងណាស់ក្នុងការស្តាប់បង្គាប់តាមទ្រង់ ឥឡូវនេះ ។ គឺព្រះអម្ចាស់បានប្រាប់ពួកគេឲ្យលាបឈាមរបស់កូនចៀមនៅលើមាត់ទ្វារផ្ទះរបស់ពួកគេ ។ នៅពេលដែលទេវតានៃសេចក្តីស្លាប់ បានឆ្លងកាត់ស្រុកនោះ នៅយប់នោះប្រសិនបើទ្រង់បានឃើញឈាមនៅឯផ្ទះនោះ នោះទ្រង់នឹងរំលងផ្ទះនោះ ដូច្នេះមនុស្សគ្រប់គ្នានៅខាងក្នុងផ្ទះនោះនឹងមានសុវត្ថិភាពជាមិនខាន ។ គ្មានក្មេងណាម្នាក់ត្រូវស្លាប់ឡើយ ។ នោះហើយជាមូលហេតុដែលគេហៅថា បុណ្យរំលង ។ យប់បានមកដល់ នៅពេលដែលទេវតាកំពុងដើរកាត់ ។ ក្មេងៗជាច្រើនបានស្លាប់ រួមទាំងកូនប្រុសរបស់ស្តេចផារ៉ោន ។ ប៉ុន្តែជន ជាតិអ៊ីស្រាអែលបានស្តាប់បង្គាប់ព្រះអម្ចាស់ ដូច្នេះហើយកូនៗរបស់ពួកគេទាំងអស់បានមានសុវត្ថិភាព។ នៅទីបំផុត ស្តេចផារ៉ោនបានត្រូវបញ្ចុះបញ្ចូលដោយអំណាចនៃព្រះចេស្តារបស់ព្រះ ហើយគាត់ក៏ព្រមដោះលែងឲ្យជនជាតិអ៊ីស្រាអែលចេញទៅ ។ នេះជាបុណ្យរំលងលើកទី១ ។ ព្រះទ្រង់បានប្រាប់ជនជាតិអ៊ីស្រាអែលទាំងអស់ ដើម្បីឲ្យចងចាំយប់នេះជានិច្ច ។ សូម្បីតែសព្វថ្ងៃនេះ យើងចងចាំ និងអបអរសាទរនូវពេលវេលាដ៏ពិសេសនេះ នៅពេលដែលព្រះអម្ចាស់បានរំដោះប្រជាជនរបស់ព្រះអង្គ ។ **(និក្ខមនំ ជំពូក ៣ - ១២)**

2.09 **បុណ្យរំលងលើកទី១ - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន**

**កំណត់សម្គាល់**:

១) ព្រះទ្រង់បានចាត់លោកម៉ូសេ ឲ្យទៅជួយរំដោះជនជាតិអ៊ីស្រាអែលពីស្តេចផារ៉ោន ។

២) ផារ៉ោនជាមនុស្សរឹងចចេស ហើយគិតថាខ្លួនគាត់មានអំណាចដូចជាព្រះ ។

៣) គ្រោះកាចទាំង១០បានកើតមានលើប្រជាជនអេស៊ីព្ទ ។

៤) គ្រោះកាចចុងក្រោយអាចនឹងធ្វើឱ្យកូនច្បងនៃគ្រួសារនីមួយៗត្រូវស្លាប់ ។

៥) ព្រះទ្រង់បានការពារពួកកូនចៅអ៊ីស្រាអែល នៅពេលដែលឪពុកម្តាយពួកគេ បានស្តាប់បង្គាប់តាមទ្រង់ ដោយបានលាបឈាមកូនចៀមនៅលើមាត់ទ្វារនៃផ្ទះរបស់ពួកគេ ។

៦) ស្តេចផារ៉ោនបានព្រមអនុញ្ញាត ឲ្យប្រជាជនអ៊ីស្រាអែលចាកចេញទៅ ។ នៅទីបំផុតគាត់រៀនបានថា ព្រះមានអំណាចបំផុត ។

**សំណួរ**:

1) ហេតុអ្វីបានជាជនជាតិអ៊ីស្រាអែលចង់ចាកចេញពីស្រុកអេស៊ីព្ទ?

2) តើព្រះទ្រង់បានសុំអ្នកណាឲ្យទៅជួយសង្គ្រោះប្រជាជនអ៊ីស្រាអែល?

3) តើព្រះទ្រង់បានបណ្តាលឲ្យមានគ្រោះកាចប៉ុន្មានកើតឡើង?

4) តើអ្វីជាគ្រោះកាចដ៏អាក្រក់បំផុត?

5) តើប្រជាជនអ៊ីស្រាអែលអាចការពារកូនៗរបស់ពួកគេយ៉ាងដូចម្តេច?

6) តើមានរឿងអ្វីកើតឡើង នៅពេលដែលគ្រោះកាចចុងក្រោយត្រូវបានបញ្ចប់?

**ចម្លើយ**:

1) ស្តេចផារ៉ោនជាមនុស្សអាក្រក់ ហើយបានដាក់ឱ្យប្រជាជនអ៊ីស្រាអែលធ្វើការយ៉ាងខ្លាំង ។

2) ព្រះបានសុំឲ្យលោកម៉ូសេទៅជួយសង្គ្រោះជនជាតិអ៊ីស្រាអែល។

3) ព្រះបានបណ្តាលឲ្យមានគ្រោះកាច១០យ៉ាង ។

4) គ្រោះកាចដ៏អាក្រក់បំផុតនោះ គឺការស្លាប់នៃកូនច្បង ។

5) ជនជាតិអ៊ីស្រាអែលបានស្តាប់បង្គាប់ព្រះ ដោយបានលាបឈាមរបស់កូនចៀម នៅលើមាត់ទ្វារផ្ទះរបស់ពួកគេ

6) ស្តេចផារ៉ោនបានឲ្យជនជាតិអ៊ីស្រាអែលចេញទៅ ។ គាត់បានដឹងថា ព្រះគឺមានអំណាចបំផុត ។



Kids of Destiny®
Reaching the Next Generation

www.kidsofdestiny.org